ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ..........................................

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមករាឆ្នាំ២០១៧

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី សន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៦ និង ទិសដៅការងារឆ្នាំ២០១៧ របស់ធនាគារជាតិនៃកម្ពុជា

នៅថ្ងៃទី២១-២២ ខែមករា ឆ្នាំ២០១៧ ធនាគារជាតិនៃកម្ពុជាបានរៀបចំសន្និបាតបូកសរុបលទ្ធផលការងាររបស់ធនាគារជាតិនៃកម្ពុជាប្រចាំឆ្នាំ២០១៦ និងទិសដៅការងារឆ្នាំ២០១៧ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម ជា ចាន់តូ ទេសាភិបាល ធនាគារជាតិនៃកម្ពុជា។ គោលបំណងនៃសន្និបាទនេះ គឺដើម្បីអបអរសាទរ និងផ្សព្វផ្សាយឱ្យកាន់តែទូលំទូលាយអំពីសមិទ្ធផលដែលធនាគារជាតិនៃកម្ពុជាទទួលបាននៅឆ្នាំ២០១៦ ព្រមទាំងទស្សនវិស័យនិងទិសដៅការងារឆ្នាំ២០១៧ ក្នុងការឈានទៅសម្រេចឱ្យបានជោគជ័យថ្មីៗបន្ថែមទៀត។

នៅឆ្នាំ២០១៦នេះ ថ្វីបើសេដ្ឋកិច្ចពិភពលោកបន្តងើបឡើងក្នុងល្បឿនយឺតនៅឡើយ សេដ្ឋកិច្ចកម្ពុជាបន្តមានកំណើនរឹងមាំ ក្នុងរង្វង់ ៧% គាំទ្រជាចម្បងដោយកំណើនរឹងមាំនៃការនាំចេញផលិតផលសម្លៀកបំពាក់និងស្បែកជើង កំណើនក្នុងវិស័យសំណង់និងអចលនទ្រព្យ និងវិស័យទេសចរណ៍ ស្របពេលដែលវិស័យកសិកម្មបានងើបឡើងវិញបន្តិច។ កម្ពុជាក៏រក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងស្ថិរភាពហិរញ្ញវត្ថុ ប្រកបដោយភាពរឹងមាំផងដែរ។ អត្រាអតិផរណាបានបន្តស្ថិតក្នុងកម្រិតទាបជាមធ្យម ២,៩% នៅឆ្នាំ២០១៦ ជាចម្បងដោយសារកម្រិតទាបនៃថ្លៃប្រេង និងការអនុវត្តគោលនយោបាយសារពើពន្ធ រូបិយវត្ថុ និងអត្រាប្តូរប្រាក់ សមស្របទៅនឹងកំណើនសកម្មភាពសេដ្ឋកិច្ច។ តម្លៃប្រាក់រៀលមានស្ថិរភាព ក្នុងកម្រិតជាមធ្យម ៤.០៥០រៀល ក្នុងមួយដុល្លារអាមេរិក។ គិតត្រឹមចុងឆ្នាំ២០១៦ ទុនបម្រុងអន្តរជាតិបានកើនដល់ ៦,៤ប៊ីលានដុល្លារអាមេរិក ដែលអាចធានាដល់ការទូទាត់ការនាំចូលទំនិញនិងសេវាបានប្រមាណ ៥ខែ។

វិស័យធនាគារកម្ពុជា បន្តរីកចម្រើនប្រកបដោយភាពរឹងមាំវិសាលភាពកាន់តែទូលំទូលាយ និងបរិយាប័ន្ន។ ប្រាក់បញ្ញើបានកើនដល់ ៦៤% នៃផ.ស.ស (កំណើន ១៨%) ហើយឥណទានទៅកាន់វិស័យឯកជនបានកើនដល់ ៧១% នៃផ.ស.ស (កំណើន ២២%)។ ល្បឿនកំណើនឥណទានមាននិន្នាការថយចុះសន្សឹមៗ។ បន្ថែមលើនេះ ប្រភពទុនភាគច្រើនមានស្ថិរភាព ហើយសំពៀតឥណទានមានគុណភាពល្អ ឆ្លុះបញ្ចាំងតាមរយៈកម្រិតទាបនៃឥណទានមិនដំណើរការ។

ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

សម្រាប់ទស្សនវិស័យឆ្នាំ២០១៧ កំណើនសេដ្ឋកិច្ចពិភពលោកត្រូវបានព្យាករថានឹងមានអត្រា ៣,៥% ខ្ពស់ជាងឆ្នាំ២០១៦។ រីឯសេដ្ឋកិច្ចកម្ពុជាត្រូវបានប៉ាន់ស្មានថានឹងបន្តស្ថិតលើគន្លងនៃកំណើនរយៈពេលវែង ក្នុងអត្រាខ្ពស់ប្រមាណ ៧% នៅឆ្នាំ២០១៧ ជាមួយនឹងការកើនឡើងនៃអតិផរណាបន្តិចប្រមាណ ៣% ខណៈដែលអត្រាប្តូរប្រាក់នឹងរំពឹងថាបន្តមានស្ថិរភាពល្អប្រសើរក្នុងរង្វង់ ៤.០៥០រៀលក្នុងមួយដុល្លារអាមេរិក។

**ទំនាក់ទំនង ៖**
ផ្នែកទំនាក់ទំនង, ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៩៩០ ១៩៦
អ៊ីម៉ែល ៖ nbccommunication@nbc.org.kh